**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ៦៤ អនក្រ**

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការជាតិត្រួតពិនិត្យការអនុវត្តអនុសញ្ញាអន្តរជាតិខាងការងារ ដែលកម្ពុជាបានផ្តល់សច្ចាប័ន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ២៨៣អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១ ._**

ត្រូវបានបង្កើត គណៈកម្មការជាតិត្រួតពិនិត្យការអនុវត្តអនុសញ្ញាអន្តរជាតិខាងការងារ ដែលកម្ពុជាបានផ្តល់សច្ចាប័ន (អក្សរកាត់សរសេរថា គ. ត. អ. ក) ជាស្ថាប័នត្រីភាគី មានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| - រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ០១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ០១រូប | អនុប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ០១រូប | សមាជិក |
| - អគ្គស្នងការនគរបាលជាតិ | ០១រូប | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | ០១រូប | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១រូប | សមាជិក |
| - តំណាងសហជីព | ០៤រូប | សមាជិក |
| - តំណាងសមាគមនិយោជក | ០៤រូប | សមាជិក |
| - តំណាងក្រសួងស្ថាប័នពាក់ព័ន្ធ | | សមាជិក។ |

**ប្រការ២ ._**

គណៈកម្មការនេះ មានតួនាទី និងភារកិច្ច ដូចតទៅ៖

- ពិនិត្យ និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលកម្ពុជាទាក់ទងដល់ការផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិខាងការងារ និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ ឬការដកខ្លួនចេញពីអនុសញ្ញាអន្តរជាតិខាងការងារ ឬអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ ដែលកម្ពុជាបានផ្តល់សច្ចាប័នរួចហើយ
- តាមដាន និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើរបាយការណ៍ ជូនស្ថាប័នអន្តរជាតិស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិខាងការងារ ដែលកម្ពុជាបានផ្តល់សច្ចាប័ន និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ
- រៀបចំរបាយការណ៍បំភ្លឺករណីបណ្តឹងនានានៅអង្គការអន្តរជាតិខាងការងារ និងអង្គការអន្តរជាតិផ្សេងៗពាក់ព័ន្ធនឹងអនុសញ្ញាអន្តរជាតិខាងការងារ
- ពិនិត្យ និងចាត់ចែងការចុះស្រាវជ្រាវលើអង្គហេតុនិងអង្គច្បាប់ ប្រមូលព័ត៌មាន និងភស្តុតាង នៃករណីបណ្តឹងនានាពាក់ព័ន្ធនឹងការអនុវត្តអនុសញ្ញាអន្តរជាតិខាងការងារ និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ
- សម្របសម្រួល និងចាត់ចែងឱ្យមានការដោះស្រាយបញ្ហានានា ពាក់ព័ន្ធនឹងការអនុវត្តអនុសញ្ញាអន្តរជាតិខាងការងារ និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ
- ប្រជុំប្រចាំត្រីមាស ឆមាស និងតាមការចាំបាច់ ដើម្បីពិនិត្យស្ថានភាព និងលើកយោបល់សម្រាប់ការដោះស្រាយរាល់បញ្ហានានានៃការអនុវត្តអនុសញ្ញាអន្តរជាតិខាងការងារ និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ
- ពិនិត្យ និងលើកសំណើជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចលើថវិកាចំណាយប្រចាំឆ្នាំរបស់គណៈកម្មការ
- បំពេញការងារចាំបាច់ផ្សេងទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

គណៈកម្មការ អាចអញ្ជើញអ្នកជំនាញ ឬបុគ្គលណាមួយ ឬតំណាងស្ថាប័នណាមួយ ឬអង្គភាពណាមួយ ចូលរួមប្រជុំ ដើម្បីពិគ្រោះយោបល់ ឬផ្តល់ឯកសារ ភស្តុតាង និងព័ត៌មានផ្សេងៗ ទៅតាមករណីអនុវត្តអនុសញ្ញានីមួយៗ ទៅតាមការចាំបាច់។

**ប្រការ៣ .-**

គណៈកម្មការនេះ មានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលស្ថិតនៅក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាសេនាធិការ ទទួលបន្ទុកការងារដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់គណៈកម្មការ
- រៀបចំកិច្ចប្រជុំនានារបស់គណៈកម្មការ
- សហការជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីរៀបចំការស៊ើបអង្កេតករណីបណ្តឹងតវ៉ា ក្នុងករណីចាំបាច់
- រៀបចំសេចក្តីព្រាងរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិខាងការងារ និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ និងការបំភ្លឺលើករណីបណ្តឹងពាក់ព័ន្ធនឹងការអនុវត្តអនុសញ្ញាទាំងនេះ ជូនគណៈកម្មការពិនិត្យ និងស្នើសុំសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំនីមួយៗ សម្រាប់ដំណើរការគណៈកម្មការដើម្បីដាក់ជូនគណៈកម្មការពិនិត្យនិងលើកសំណើជូនរាជរដ្ឋាភិបាលពិនិត្យសម្រេច
- អនុវត្តភារកិច្ចផ្សេងទៀត ដែលគណៈកម្មការប្រគល់ជូន។

សមាសភាពរបស់លេខាធិការដ្ឋាននឹងត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ៤ .-**

សេចក្តីសម្រេចលេខ៤៤ សសរ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៥ ស្តីពី ការបង្កើតគណៈកម្មការអន្តរក្រសួងស៊ើបអង្កេតពិសេសលើករណីបណ្តឹងលេខ២៣១៨ ស្តីពីករណីឃាតកម្មលើមេដឹកនាំសហជីព ជា វិជ្ជា ហ៊ី វុទ្ធី និង រស់ សុវណ្ណារ៉េត និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងស្ថាប័នដែលពាក់ព័ន្ធ តំណាងសហជីព និងតំណាងសមាគមនិយោជកត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ សីហា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ